# ការអនុវត្តន៍ល្អ
## អ្នកពន្លត់អគ្គីភ័យ

**រោងចក្រ កាន់តែប្រសើរ នៅកម្ពុជា**

វាគឺជាគំនិតមួយយ៉ាងល្អ ក្នុងការបង្កើតអោយមានក្រុមពន្លត់អគ្គីភ័យ ។ ការឆ្លើយតបយ៉ាងឆាប់រហ័សចំពោះអគ្គីភ័យ អាចសន្សំសំចៃថវិកាតាមរយៈការកាត់បន្ថយឱកាសដែលបង្ករគ្រោះថ្នាក់ធ្ងន់ធ្ងរចំពោះមនុស្ស ឬទ្រព្យសម្បត្តិ ។ ផ្តល់សញ្ញាសំគាល់អោយទៅអ្នកពន្លត់អគ្គីភ័យ ដើម្បីអោយកម្មករដទៃទៀតដឹងថា ជាអ្នកដែលពួកគេត្រូវសុំជំនួយ ក្នុងករណីដែលមានគ្រោះអាសន្ន ។ សូមមើលផងដែរ សេចក្តីណែនាំការអនុវត្តន៍ល្អស្តីពី សុវត្ថិភាពអគ្គីភ័យ និងបំពង់ពន្លត់អគ្គីភ័យ ។

### ការអនុវត្តន៍ល្អសំរាប់អ្នកពន្លត់អគ្គីភ័យ

ចូរបង្កើតក្រុមពន្លត់អគ្គីភ័យ ។ យ៉ាងហោចណាស់ ត្រូវមានអ្នកពន្លត់អគ្គីភ័យម្នាក់ សំរាប់ផ្នែក/ជាន់នីមួយៗ របស់រោងចក្រ ។

ផ្តល់សញ្ញាសំគាល់អោយអ្នកពន្លត់អគ្គីភ័យ ។ ទំរង់សញ្ញាសំគាល់ដែលច្បាស់ គឺផ្ទាំងក្រណាត់ពាក់ជុំវិញដៃ ដែលមានពណ៌ភ្លឺឆើត (រូបភាពទី១) ។

ទំរង់សញ្ញាសំគាល់ដែលច្បាស់ម្យ៉ាងទៀត គឺអោយអ្នកពន្លត់អគ្គីភ័យពាក់សញ្ញាសំគាល់លើអាវរបស់ពួកគេ (រូបភាពទី២) ។

រូបថតរបស់អ្នកពន្លត់អគ្គីភ័យ គួរត្រូវបានដាក់បង្ហាញអោយកម្មករទាំងអស់មើលឃើញ ។

ជារឿងសំខាន់ ដែលអ្នកពន្លត់អគ្គីភ័យទទួលបានការហាត់ហ្វឹកហ្វឺនជាប្រចាំ ហើយចំនួនអ្នកពន្លត់អគ្គីភ័យត្រូវសមាមាត្រជាមួយនឹងកំលាំងពលកម្មសរុប ។



រូបភាពទី១



រូបភាពទី២

### អត្ថប្រយោជន៍:

- ✓ បង្ហាញទស្សនៈល្អនៃកន្លែងធ្វើការដែលប្រកបដោយការទទួលខុសត្រូវ
- ✓ ក្នុងករណីមានគ្រោះអគ្គីភ័យ គេស្រួលចំណាំអ្នកពន្លត់អគ្គីភ័យ ហើយអាចចាត់វិធានការណ៍បានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធិភាព
- ✓ ចាត់វិធានការណ៍ចំពោះអគ្គីភ័យទាន់ពេលវេលា អាចសន្សំថវិកា និងសង្គ្រោះអាយុជីវិតកម្មករ

### តាមរបៀបណា:

- ✓ បង្កើតក្រុមពន្លត់អគ្គីភ័យនៅតាមផ្នែក/ជាន់នីមួយៗ
- ✓ ផ្តល់ការហាត់ហ្វឹកហ្វឺនដល់អ្នកពន្លត់អគ្គីភ័យ
- ✓ ផ្តល់ផ្លាកសញ្ញាសំគាល់ដល់អ្នកពន្លត់អគ្គីភ័យ ដោយប្រើក្រណាត់សំរាប់ :
  - ➢ ឯកសណ្ឋាន និង/ឬ
  - ➢ ផ្លាកសំគាល់ និង/ឬ
  - ➢ ក្រណាត់ពាក់ជុំវិញដៃ

### តំលៃ:

**$**

- $ តំលៃទាប
- $$ តំលៃមធ្យម
- $$$ តំលៃខ្ពស់